

# យុទ្ធសាស្ត្រ

# ស្តីពី

# ការផ្សព្វផ្សាយព័ត៌មានក្រុមប្រឹក្សាស្រុកសង្កែ

# ខេត្តបាត់ដំបង

ឧសភា ២០១៤

# មាតិកា

**១. សេចក្តីផ្តើម**.......................................................................................................3

**២ យុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មាន**.......................................................................................3

២.១ ក្រុមផ្សព្វផ្សាយព័ត៌មាន.....................................................................................................4

២.១.១ សមាសភាពក្រុមផ្សព្វផ្សាយព័ត៌មានស្រុកសង្កែ.......................................................................4

២.១.២ ភារកិច្ចរបស់ប្រធានក្រុមផ្សព្វផ្សាយព័ត៌មានស្រុកសង្កែ...............................................................4

២.១.៣ ភារកិច្ចរបស់សមាជិកក្រុមផ្សព្វផ្សាយព័ត៌មានស្រុកសង្កែ...............................................................4

២.១.៤ មធ្យោបាយផ្សព្វផ្សាយ និងប្រភេទព័ត៌មាន...........................................................................4

២.១.៥ ប្រភេទព័ត៌មានជាអាទិភាពត្រូវផ្សព្វផ្សាយ ..........................................................................5

២.២ អនុស្សារណៈយោគយល់គ្នា ជាមួយមន្ទីរព័ត៌មានខេត្តបាត់ដំបង ស្តីពីការផ្សព្វផ្សាយព័ត៌មាន .....................5

**៣. សេចក្តីសន្និដ្ឋាន**.......................................................................................................6

**ឧបសម្ព័ន្ធ** ..................................................................................................................7

ឧបសម្ព័ន្ធ "ក"៖ តារាងយុទ្ធសាស្ត្រសង្ខេបស្តីពីការផ្សព្វផ្សាយព័ត៌មានរបស់ស្រុកសង្កែ..................................7

ឧបសម្ព័ន្ធ "ខ"៖ សេចក្តីរៀបរាប់លំអិតអំពីមាត្រានានានៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ពីការផ្សព្វផ្សាយព័ត៌មាន....................................................................13

ឧបសម្ព័ន្ធ "គ"៖ សេចក្តីសម្រេច និងលក្ខខណ្ឌការងារក្រុមការងារផ្សព្វផ្សាយព័ត៌មាន...................................14

## ១. សេចក្ដីផ្ដើម

នៅក្នុងឆ្នាំ២០១០ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានតាក់តែងឡើង ជារបៀបវារៈការងាររបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងដំណើរការកំណែទម្រង់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យដ៏ទូលំទូលាយ និងស៊ីជម្រៅនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ កម្មវិធីជាតិ គឺជា សេចក្ដីណែនាំ ដើម្បីជំរុញឱ្យការផ្ដល់សេវាសាធារណៈនៅថ្នាក់ក្រោមជាតិកាន់តែប្រសើរ និងចូលរួមកាត់បន្ថយជល់ភាពក្រីក្រ។ លើកកម្ពស់សិទ្ធិទទួលព័ត៌មាន ក៏បានរំលេចនៅក្នុងកម្មវិធីជាតិ សំដៅសម្របសម្រួលឱ្យប្រជាពលរដ្ឋមានសិទ្ធិស្របច្បាប់ក្នុងការទទួលព័ត៌មានពីការសម្រេចចិត្ត និងការបំពេញភារកិច្ចរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។

ក្នុងន័យបង្ហាញអំពីអភិបាលកិច្ច និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ ជាពិសេស ការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋពីសិទ្ធិនិងតួនាទីរបស់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ តាមរយៈការទទួលបានព័ត៌មាន ក្រុមប្រឹក្សាស្រុកសង្កែ បានមើលឃើញនូវភាពចាំបាច់ ហើយក៏បានរៀបចំនូវយុទ្ធសាស្ត្រស្ដីពីការផ្សព្វផ្សាយព័ត៌មាននេះឡើង ដើម្បីលើកកម្ពស់ការទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋឱ្យកាន់តែទូលំលាយអំពីការសម្រេចចិត្ត សកម្មភាព និងសមិទ្ធិផលនានានៃការបំពេញភារកិច្ចរបស់ក្រុមប្រឹក្សាស្របតាមច្បាប់ ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានជាអាទិ៍៖ មាត្រា៣៦ មាត្រា៤១ មាត្រា៥១ មាត្រា៥២ មាត្រា៧៦ មាត្រា១៦៩ និងមាត្រា១៧០។ យុទ្ធសាស្ត្រស្ដីពីការផ្សព្វផ្សាយព័ត៌មាននេះ រៀបចំឡើង ដោយផ្អែកទៅតាមយន្តការផ្សព្វផ្សាយព័ត៌មានជាក់ស្ដែង ដែលក្រុមប្រឹក្សាស្រុកសង្កែបានអនុវត្តកន្លងមក នាឆ្នាំ២០១៣ ដោយមានការជួយឧបត្ថម្ភពីអង្គការដៃគូនានាធ្វើការនៅក្នុងស្រុកសង្កែ ជាពិសេស "គម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ" ដែលគាំទ្របច្ចេកទេសដោយអង្គការផេកនៅកម្ពុជាតាមរយៈអង្គការអមរា។

## ២ យុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មាន

យុទ្ធសាស្ត្រស្ដីពីការផ្សព្វផ្សាយព័ត៌មានរៀបចំឡើង ក្នុងគោលបំណង៖

១) លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពី៖ សកម្មភាពអភិវឌ្ឍន៍នៅក្នុងដែនសមត្ថកិច្ច សមិទ្ធិផលនៃការបំពេញភារកិច្ច និងការសម្រេចចិត្តនានារបស់ក្រុមប្រឹក្សាស្រុកសង្កែ។

២) បង្ហាញពីបទពិសោធន៍ជោគជ័យក្នុងការលើកកម្ពស់ការទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយសារមានយុទ្ធសាស្ត្រស្ដីពីការផ្សព្វផ្សាយព័ត៌មាន។

យន្តការជាយុទ្ធសាស្ត្រ សំខាន់ចំនួនពីរ ដែលក្រុមប្រឹក្សាស្រុកសង្កែបានប្រើប្រាស់រួមមាន៖

១. សេចក្ដីសម្រេចស្ដីពីការបង្កើតក្រុមផ្សព្វផ្សាយព័ត៌មាន និងការអនុវត្តការងារផ្សព្វផ្សាយ។

២. អនុស្សារណៈយោគយល់គ្នារវាងក្រុមប្រឹក្សាស្រុកសង្កែជាមួយ មន្ទីរព័ត៌មានខេត្តបាត់ដំបង ស្ដីពីកិច្ចសហការផ្សព្វផ្សាយព័ត៌មាន។






៥

## ២.១ ក្រុមផ្សព្វផ្សាយព័ត៌មាន

ក្រុមផ្សព្វផ្សាយព័តិមានគឺជាយន្តការមួយ ដែលមានរចនាសម្ព័ន្ធច្បាស់លាស់បញ្ជាក់អំពី៖ សមាសភាព មធ្យោបាយ និងប្រភេទព័តិមានដែលត្រូវផ្សព្វផ្សាយ ។

### ២.១.១ សមាសភាពក្រុមផ្សព្វផ្សាយព័ត៌មានស្រុកសង្កែ

ដើម្បីធានាឱ្យការផ្សព្វផ្សាយព័តិមានបានដល់ប្រជាពលរដ្ឋ និងងាយស្រួលដល់ការគ្រប់គ្រង សមាសភាពសំខាន់ៗនៃក្រុមផ្សព្វផ្សាយព័តិមាន សម្រេចឱ្យមានការចូលរួមពី៖

- អភិបាលរងស្រុក ១រូប (ជាស្ត្រី) ជាប្រធាន
- សមាជិកក្រុមប្រឹក្សាស្រុក ១រូប ជាអនុប្រធាន
- តំណាងមន្ទីរព័តិមានខេត្ត ១រូប ជាសមាជិក
- តំណាង (ប្រធាន) បណ្តាញសហគមន៍មូលដ្ឋាន ១រូប ជាសមាជិក
- នាយករងរដ្ឋបាលសាលាស្រុក ១រូប ជាលេខាធិការ

### ២.១.២ ភារកិច្ចរបស់ប្រធានក្រុមផ្សព្វផ្សាយព័ត៌មានស្រុកសង្កែ

ភារកិច្ចសំខាន់ៗរបស់ប្រធានក្រុមផ្សព្វផ្សាយព័តិមាន រួមមាន៖

- កសាងផែនការសកម្មភាពនៃការផ្សព្វផ្សាយព័តមានឱ្យបានទៀងទាត់ ត្រឹមត្រូវ និងច្បាស់លាស់
- ដឹកនាំ និងគ្រប់គ្រងក្រុមផ្សព្វផ្សាយព័តិមាន
- ផ្តល់ព័តិមានទាំងឡាយដែលកំណត់ដោយក្របខណ្ឌការងារដល់សមាជិក ដើម្បីឱ្យជួយផ្សព្វផ្សាយបន្តទៅដល់ប្រជាពលរដ្ឋ
- រាយការណ៍អំពីស្ថានភាពនៃការផ្សព្វផ្សាយជូនក្រុមប្រឹក្សាក្នុងរាល់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាស្រុក
- រៀបចំកិច្ចសន្យាជាមួយអ្នកផ្តល់សេវាផ្សព្វផ្សាយព័តិមាន
- រៀបចំគម្រោងថវិកាសម្រាប់គាំទ្រដល់ការចំណាយផ្សេងៗ មានការថតចម្លងឯកសារ ការបោះពុម្ពសម្ភារសម្រាប់យកទៅផ្សព្វផ្សាយ និងអប់រំដល់ប្រជាពលរដ្ឋ
- រៀបចំប្រជុំក្រុមផ្សព្វផ្សាយព័តិមានឱ្យបានទៀងទាត់ ដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាពនៃការផ្សព្វផ្សាយ និងធ្វើការបូកសរុបលទ្ធផលនៃការផ្សព្វផ្សាយ ដើម្បីរាយការណ៍ក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុក។

### ២.១.៣ ភារកិច្ចរបស់សមាជិកក្រុមផ្សព្វផ្សាយព័ត៌មានស្រុកសង្កែ

ភារកិច្ចសំខាន់ៗរបស់សមាជិកក្រុមផ្សព្វផ្សាយព័តិមាន រួមមាន៖

- ពាំនាំព័តិមានពីប្រធាន និងក្រុមប្រឹក្សាស្រុក យកទៅផ្សព្វផ្សាយជូនប្រជាពលរដ្ឋឱ្យបានទៀងទាត់
- ផ្តល់យោបល់ត្រឡប់ និងរាយការណ៍អំពីមតិយោបល់របស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងការផ្សព្វផ្សាយព័តិមាន
- ចូលរួមក្នុងកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាស្រុក

### ២.១.៤ មធ្យោបាយផ្សព្វផ្សាយ និងប្រភេទព័ត៌មាន

មធ្យោបាយសំខាន់ៗ ដែលក្រុមប្រឹក្សាស្រុកប្រើប្រាស់ជាយុទ្ធសាស្ត្រ ដើម្បីធានាថាការផ្សព្វផ្សាយព័តិមានបានដល់ប្រជាពលរដ្ឋ រួមមាន៖



៥

១) ការចុះពិគ្រោះយោបល់នៅមូលដ្ឋាន

២) វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់

៣) កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាស្រុក

៤) ឧត្បាសនស័ព្ទ (មេក្រូ)

៥) ក្តារព័ត៌មាន

៦) តំណាងក្រុមប្រឹក្សាឃុំ

៧) បណ្តាញសហគមន៍មូលដ្ឋាន

### ២.១.៥ ប្រភេទព័ត៌មានជាអាទិភាពត្រូវផ្សព្វផ្សាយ

ប្រភេទព័ត៌មាន ជាយុទ្ធសាស្ត្រដែលក្រុមប្រឹក្សាស្រុកសង្កែបានផ្សព្វផ្សាយ រួមមាន៖

- ✓ តួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាស្រុកសង្កែ
- ✓ របៀបវារៈ និងប្រតិទិននៃ៖ កិច្ចប្រជុំប្រចាំខែ ការចុះពិគ្រោះយោបល់នៅមូលដ្ឋាន វេទិកាផ្សព្វផ្សាយនិងពិគ្រោះ យោបល់របស់ស្រុកសង្កែ
- ✓ កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំប្រចាំខែ ជាពិសេសការពិភាក្សាពីការដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋការសម្រេចចិត្តនានារបស់ក្រុមប្រឹក្សាស្រុកដែលមានឥទ្ធិពល ឬផលប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ
- ✓ គម្រោងអភិវឌ្ឍន៍សង្គមនានាក្នុងមូលដ្ឋានដូចជា៖ គាំពារសុខភាពមាតានិងទារក អាហារូបត្ថម្ភ ការអប់រំ សេវាសុខភាព អនាម័យខ្លួនប្រាណនិងការប្រើប្រាស់បង្គន់អនាម័យ ការទទួលបានទឹកសុវត្ថិភាព ការចុះបញ្ជីអត្រានុកូលដ្ឋាន និងសន្តិសុខសុវត្ថិភាព
- ✓ គម្រោងអភិវឌ្ឍន៍ក្នុងមូលដ្ឋានដូចជា ៖ ការស្ថាបនា ស្ពាន ថ្នល់ ទំនប់ ប្រឡាយ ប្រព័ន្ធលូ ធារាសាស្ត្រ សម្បទានដីធ្លី
- ✓ ប្រកាសជូនដំណឹងគម្រោងអភិវឌ្ឍន៍ដែលបានអនុម័ត និងសម្រេចដាក់ចូលក្នុងកម្មវិធីវិនិយោគស្រុក
- ✓ គម្រោងផែនការថវិកាចំណូល ចំណាយរបស់ក្រុមប្រឹក្សាស្រុក
- ✓ អត្រាតម្លៃសេវាសាធារណៈរបស់ក្រុមប្រឹក្សាស្រុកដែលបានកំណត់ដោយថ្នាក់ជាតិ
- ✓ ព័ត៌មានទាក់ទងនឹងផលប្រយោជន៍ និងតម្រូវការរបស់ក្រុមជនងាយរងគ្រោះ ស្ត្រី យុវជន
- ✓ ចំណាត់ការ និងដំណោះស្រាយ ឆ្លើយតបទៅនឹងបញ្ហាដែលប្រជាពលរដ្ឋបានលើកឡើង។

## ២.២ អនុស្សារណៈយោគយល់គ្នា ជាមួយមន្ទីរព័ត៌មានខេត្តបាត់ដំបង ស្តីពីការផ្សព្វផ្សាយព័ត៌មាន

ក្រៅពីក្រុមការងារផ្សព្វផ្សាយព័ត៌មាន ក្រុមប្រឹក្សាស្រុកសង្កែ យល់ឃើញថា ប្រព័ន្ធផ្សព្វផ្សាយ គឺជាយុទ្ធសាស្ត្រដ៏សំខាន់ ជួយជំរុញការផ្សព្វផ្សាយព័ត៌មានជាសាធារណៈឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋទូទាំងប្រទេសដោយហេតុដូច្នេះហើយទើប ក្រុមប្រឹក្សាស្រុកសង្កែបានចុះអនុស្សារណៈយោគយល់គ្នា ស្តីពីកិច្ចសហការផ្សព្វផ្សាយព័ត៌មានជាមួយមន្ទីរ



៥

ព័ត៌មានខេត្តបាត់ដំបង ដើម្បីពង្រីកវិសាលភាព និងធានាថា ប្រជាពលរដ្ឋ ជាពិសេសក្នុងស្រុកសង្កែទទួលបានព័ត៌មានជាក់លាក់ និងទាន់ពេលវេលា។

## ៣. សេចក្តីសន្និដ្ឋាន

ការសម្រេចបង្កើតយុទ្ធសាស្ត្រស្តីពី ការផ្សព្វផ្សាយព័ត៌មាននេះឡើង ដោយក្រុមប្រឹក្សាស្រុកសង្កែ ដើម្បីប្រើប្រាស់ជាយន្តការ និងជាមគ្គុទ្ទេស ពីក្រុមប្រឹក្សាស្រុកឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ សម្រាប់ចែករំលែកដំណឹង ព្រឹត្តិការណ៍ ហេតុការណ៍ពិត សំខាន់ និងទាន់ពេលវេលា អំពីសកម្មភាពនៃការបំពេញការងារ សមិទ្ធផល និងការសម្រេចដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ ។

យុទ្ធសាស្ត្រស្តីពីការផ្សព្វផ្សាយព័ត៌មានស្រុកសង្កែនេះ ត្រូវបានអនុម័តដោយយោងតាមស្មារតីអង្គប្រជុំរបស់ក្រុមប្រឹក្សាស្រុកនាថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០១៤។

ស្រុកសង្កែ, ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០១៤

**ប្រធានក្រុមប្រឹក្សាស្រុកសង្កែ**

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ "ក"÷ តារាងយុទ្ធសាស្ត្រសង្ខេបស្តីពីការផ្សព្វផ្សាយព័ត៌មានរបស់ស្រុកសង្កែ

| មធ្យោបាយជាយុទ្ធសាស្ត្រ | សកម្មភាពអនុវត្ត | ប្រភេទព័ត៌មានត្រូវផ្សព្វផ្សាយ |
|---|---|---|
| ១) ពិគ្រោះយោបល់នៅមូលដ្ឋាន | កិច្ចពិគ្រោះយល់នៅមូលដ្ឋានរបស់ក្រុមប្រឹក្សាឃុំ គឺជាមធ្យោបាយមួយផ្តល់ឱកាសឱ្យក្រុមប្រឹក្សាស្រុកអាចធ្វើការផ្សព្វផ្សាយព័ត៌មានបានក្នុងពេលចុះសង្កេតការណ៍ ដូច្នេះ ដើម្បីប្រាកដថាព័ត៌មានផ្សព្វផ្សាយមានផលប្រយោជន៍ លើកទឹកចិត្តដល់ការចូលរួមរបស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សាស្រុក៖<br>**មុនពេលចុះសង្កេតការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សឃុំ៖**<br>• កំណត់ និងអនុម័តប្រភេទព័ត៌មានដែលក្រុមប្រឹក្សាស្រុកត្រូវយកទៅផ្សព្វផ្សាយនៅពេលក្រុមប្រឹក្សាស្រុកចុះសង្កេតក្រុមប្រឹក្សាឃុំចុះពិគ្រោះយោបល់នៅមូលដ្ឋាន<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មានរៀបចំផលិតព័ត៌មានសង្ខេបទៅតាមការអនុម័ត របស់ក្រុមប្រឹក្សាស្រុកសម្រាប់យកទៅផ្សព្វផ្សាយនៅពេលចុះសង្កេតការពិគ្រោះយោបល់នៅមូលដ្ឋាន<br>• ស្នើសុំក្រុមប្រឹក្សាឃុំគោលដៅទុកពេលវេលាក្នុងរបៀបវារៈសម្រាប់ចែករំលែកព័ត៌មានតាមការអនុម័តដោយក្រុមប្រឹក្សាស្រុក<br>**អំឡុងពេលចុះសង្កេត ការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ៖**<br>• ផ្សព្វផ្សាយព័ត៌មាន តាមការរៀបចំដោយក្រុមផ្សព្វផ្សាយព័ត៌មាន<br>• កត់ត្រាបញ្ហាប្រជាពលរដ្ឋលើកឡើងក្នុងពេលសង្កេត<br>**ក្រោយពេលចុះសង្កេត ការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ៖**<br>• រៀបចំរបាយការណ៍ និងរាយការណ៍ជូនក្រុមប្រឹក្សាស្រុកក្នុងកិច្ចប្រជុំប្រចាំខែ | ខាងក្រោម គឺជាប្រភេទព័ត៌មានសក្តានុពលដែលក្រុមប្រឹក្សាស្រុកនឹងយកទៅផ្សព្វផ្សាយក្នុងពេលចុះសង្កេត៖<br>• បញ្ហា និងសេចក្តីត្រូវការបានដាក់ក្នុងកម្មវិធីវិនិយោគស្រុក (DIP) ឆ្នាំមុន<br>• ថវិកាចំណាយសម្រាប់គម្រោងអភិវឌ្ឍន៍ឆ្នាំមុន<br>• ថវិកាចំណាយសម្រាប់គម្រោងអភិវឌ្ឍន៍ឆ្នាំបច្ចុប្បន្ន<br>• បញ្ហា ក្តីកង្វល់ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋដែលក្រុមប្រឹក្សាស្រុកបានដោះស្រាយកន្លងមក<br>• ការបិទផ្សាយព័ត៌មានលើក្តារព័ត៌មាន |

| មធ្យោបាយជាយុទ្ធសាស្ត្រ | សកម្មភាពអនុវត្ត | ប្រភេទព័ត៌មានត្រូវផ្សព្វផ្សាយ |
| --- | --- | --- |
| ២) វេទិកាផ្សព្វផ្សាយនិង ពិគ្រោះយោបល់ | ដើម្បីធានាថាប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋានចូលរួមក្នុងវេទិកាទទួលបានព័ត៌មានដែលមានប្រយោជន៍ និងលើកកម្ពស់ភាពអង់អាច និងការចូលរួមរបស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សាស្រុក៖<br>**មុនពេលរៀបចំវេទិកា ៖**<br>• កំណត់ និងអនុម័តប្រភេទព័ត៌មានសម្រាប់យកទៅផ្សព្វផ្សាយក្នុងវេទិកា<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មានរៀបចំផលិតព័ត៌មានសង្ខេបទៅតាមការអនុម័តរបស់ក្រុមប្រឹក្សាស្រុកសម្រាប់យកទៅផ្សព្វផ្សាយនៅក្នុងវេទិកា<br>**អំឡុងពេលវេទិកា៖**<br>• ផ្សព្វផ្សាយព័ត៌មានដែលបានអនុម័តក្នុងអង្គប្រជុំ និងរៀបចំដោយក្រុមផ្សព្វផ្សាយព័ត៌មាន<br>• កត់ត្រាបញ្ហាប្រជាពលរដ្ឋលើកឡើងក្នុងវេទិកា<br>**ក្រោយពេលវេទិកា៖**<br>• រៀបចំកំណត់ហេតុសង្ខេបអំពីលទ្ធផលរបស់វេទិកា ជាពិសេសអំពីចំនួនបញ្ហាប្រជាពលដ្ឋលើកឡើងក្នុងវេទិកា ចំនួនបញ្ហាបានឆ្លើយតប និងចំណាត់ការរបស់ក្រុមប្រឹក្សាស្រុកចំពោះបញ្ហាមិនអាចដោះស្រាយបានក្នុងវេទិកាសម្រាប់ផ្សព្វផ្សាយ<br>• ផ្សព្វផ្សាយជាសាធារណៈនូវកំណត់ហេតុសង្ខេប តាមរយៈកិច្ចប្រជុំប្រចាំខែ មេក្រូ ក្ដារព័ត៌មាន បណ្ដាញសហគមន៍មូលដ្ឋាន និងប្រព័ន្ធផ្សព្វផ្សាយ ។ | ខាងក្រោម គឺជាប្រភេទព័ត៌មានសក្ដានុពលដែលក្រុមប្រឹក្សានឹងយកទៅផ្សព្វផ្សាយក្នុងវេទិកា៖<br>▪ តួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាស្រុក<br>▪ សមិទ្ធិផលសម្រេចបានក្នុងឆ្នាំកន្លងមក<br>▪ ផែនការអភិវឌ្ឍន៍របស់ស្រុកសង្ខេ ជាពិសេសគម្រោងដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ<br>▪ ថវិកាចំណាយសម្រាប់គម្រោងអភិវឌ្ឍន៍ឆ្នាំមុន និងបច្ចុប្បន្ន<br>▪ បញ្ហា ក្ដីកង្វល់ និងសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋដែលក្រុមប្រឹក្សាស្រុកបានដោះស្រាយកន្លងមក<br>▪ មូលហេតុចំពោះបញ្ហាដែលក្រុមប្រឹក្សាស្រុកមិនអាចដោះស្រាយបាន ។ |
| ៣) កិច្ចប្រជុំប្រចាំខែ ក្រុមប្រឹក្សា | ដើម្បីទាក់ទាញ លើកកម្ពស់ភាពអង់អាច ការចូលរួមរបស់ប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាន និងធានានូវការទទួលបានព័ត៌មាន ក្រុមប្រឹក្សាស្រុក៖<br>**មុនពេលកិច្ចប្រជុំប្រចាំខែ៖**<br>• កំណត់ព័ត៌មានសម្រាប់ផ្សព្វផ្សាយក្នុងកិច្ចប្រជុំប្រចាំខែ<br>• រៀបចំរបៀបវារៈកិច្ចប្រជុំចាំខែរបស់ក្រុមប្រឹក្សាស្រុក ដោយទុកពេលវេលាគ្រប់គ្រាន់សម្រាប់៖ ១) រាយការណ៍ ២)ធ្វើការបូកសរុបចំណុចសំខាន់ៗដែលមានផលប្រយោជន៍ដល់ប្រជាពលរដ្ឋក្នុងការផ្សព្វផ្សាយបន្ត និង៣) ប្រកាសព័ត៌មានអំពីប្រតិទិននៃសកម្មភាពរបស់ក្រុមប្រឹក្សាស្រុកក្នុងខែបន្ទាប់ ។ | ខាងក្រោម គឺជាប្រភេទព័ត៌មានសក្ដានុពល ដែលក្រុមប្រឹក្សាស្រុកនឹងផ្សព្វផ្សាយក្នុងពេលកិច្ចប្រជុំប្រចាំខែ ៖<br>**១) រាយការណ៍ដោយសង្ខេបអំពី៖**<br>• លទ្ធផលប្រជុំខែមុន ជាពិសេសចំនួនបញ្ហាប្រជាពលដ្ឋលើកឡើង ចំនួនបញ្ហាក្រុមប្រឹក្សាស្រុកបានឆ្លើយតប និងចំនួនបញ្ហាដែលក្រុមប្រឹក្សាស្រុកបានលើកយកមកពិភាក្សាដើម្បីចាត់វិធានការ<br>• ការប្រើប្រាស់ថវិកា (ចំណូល ចំណាយ)<br>• ផែនការអភិវឌ្ឍន៍របស់ស្រុក ជាពិសេសផែនការដែលប៉ះពាល់ |

<table>
<tr><th>មធ្យោបាយជាយុទ្ធសាស្ត្រ</th><th>សកម្មភាពអនុវត្ត</th><th>ប្រភេទព័ត៌មានត្រូវផ្សព្វផ្សាយ</th></tr>
<tr><td></td><td>ក្នុងកិច្ចប្រជុំប្រចាំខែ ៖<br>• អនុលោមទៅតាមរបៀបវារៈដែលបានអនុម័ត ឬត្រៀមទុក ។<br>ក្រោយកិច្ចប្រជុំប្រចាំខែ<br>• រៀបចំកំណត់ហេតុសង្ខេបអំពីលទ្ធផលនៃកិច្ចប្រជុំប្រចាំខែជាពិសេសអំពីចំនួនបញ្ហាប្រជាពលរដ្ឋលើកឡើងក្នុងវេទិកា  ចំនួនបញ្ហាបានឆ្លើយតប និងចំណាត់ការរបស់ក្រុមប្រឹក្សាស្រុកចំពោះបញ្ហាមិនអាចដោះស្រាយបានក្នុងវេទិកាសម្រាប់ផ្សព្វផ្សាយ<br>• ផ្សព្វផ្សាយជាសាធារណៈនូវកំណត់ហេតុសង្ខេបប្រជុំ តាមរយៈវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ មេក្រូ ក្តារព័ត៌មាន បណ្តាញសហគមន៍មូលដ្ឋាន និងប្រព័ន្ធផ្សព្វផ្សាយ ។</td><td>ដល់ប្រយោជន៍ប្រជាពលរដ្ឋ<br>• ផែនការសកម្មភាពរបស់ក្រុមប្រឹក្សាស្រុក និងចំណាត់ការ<br>២) ការបូកសរុបឡើងវិញអំពី ៖ ចំនួនបញ្ហាប្រជាពលដ្ឋលើកឡើង  ចំនួនបញ្ហាក្រុមប្រឹក្សាស្រុកបានឆ្លើយតប និងចំនួនបញ្ហាដែលក្រុមប្រឹក្សាស្រុកបានលើកយកមកពិភាក្សាដើម្បីចាត់វិធានការ<br>៣) ប្រកាសអំពីពេលវេលា ទីកន្លែង៖<br>• ប្រជុំប្រចាំខែលើកក្រោយ<br>• រៀបចំវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ (ប្រសិនបើមាន)<br>• ចុះសង្កេតក្រុមប្រឹក្សាឃុំចុះពិគ្រោះយោបល់នៅមូលដ្ឋាន កម្មវិធីវិនិយោគ (ផែនការអភិវឌ្ឍន៍) (ប្រសិនបើមាន)<br>• ធ្វើសមាហរណកម្មកម្មវិធីវិនិយោគ (ផែនការអភិវឌ្ឍន៍)<br>• ប្រកាសពីការសម្រេចចិត្ត ឬដីការ របស់ក្រុមប្រឹក្សាស្រុកដែលប៉ះពាល់ផលប្រយោជន៍ប្រជាពលរដ្ឋ (ប្រសិនបើមាន)</td></tr>
<tr><td>៤) មេក្រូ (ខ្សែគ្រាសនសំឡេ)</td><td>មេក្រូ គឺជាមធ្យោបាយមួយដែលមានភាពសាមញ្ញ និងងាយស្រួលផ្សព្វផ្សាយព័ត៌មានឱ្យដល់មូលដ្ឋានដោយផ្ទាល់ ជាពិសេសក្រុមជនងាយរងគ្រោះ ដូច្នេះដើម្បីធានាថាព័ត៌មានដែលផ្សព្វផ្សាយមានប្រយោជន៍សម្រាប់ប្រជាពលរដ្ឋ ក្រុមប្រឹក្សាស្រុក៖<br>មុនពេលផ្សព្វផ្សាយ ៖<br>• កំណត់ និងអនុម័តប្រភេទព័ត៌មានសម្រាប់យកទៅផ្សព្វផ្សាយតាមមេក្រូ<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មានរៀបចំផែនការផ្សព្វផ្សាយ និងការចំណាយសម្រាប់ការផ្សព្វផ្សាយដើម្បីដាក់ឱ្យក្រុមប្រឹក្សាអនុម័យ<br>• ចាត់ក្រុមផ្សព្វផ្សាយព័តមានផលិតព័ត៌មានសង្ខេប ទៅតាមការអនុម័តរបស់ក្រុមប្រឹក្សាស្រុក</td><td>ខាងក្រោម គឺជាប្រភេទព័ត៌មានសក្តានុពលដែលក្រុមប្រឹក្សាស្រុកនឹងផ្សព្វផ្សាយតាមរយៈមេក្រូ៖<br>▪ ពេលវេលា និងទីកន្លែងនៃកិច្ចប្រជុំប្រចាំខែ<br>▪ ពេលវេលា និងទីកន្លែងនៃការរៀបចំវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់<br>▪ ពេលវេលា និងទីកន្លែងដែលក្រុមប្រឹក្សាស្រុកចុះសង្កេតការពិគ្រោះយោបល់នៅមូលដ្ឋាន<br>▪ ស្ប៉ុតស្តីពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាស្រុក</td></tr>
</table>



ร

| មធ្យោបាយជាយុទ្ធសាស្ត្រ | សកម្មភាពអនុវត្ត | ប្រភេទព័ត៌មានត្រូវផ្សព្វផ្សាយ |
|---|---|---|
| | • ចាត់ក្រុមផ្សព្វផ្សាយព័ត៌មានចុះផ្សព្វផ្សាយទៅតាមផែនការដែលអនុម័តរបស់ក្រុមប្រឹក្សាស្រុក<br>**ក្នុងពេលផ្សព្វផ្សាយ**<br>• ចុះផ្សព្វផ្សាយទៅតាមផែនការដែលអនុម័តដោយក្រុមប្រឹក្សាស្រុក<br>• ប្រមូលព័ត៌មានត្រលប់ពីប្រជាពលរដ្ឋចំពោះការផ្សព្វផ្សាយព័ត៌មានរបស់ក្រុមប្រឹក្សាស្រុក<br>**ក្រោយផ្សព្វផ្សាយព័ត៌មាន**<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មានរៀបចំរបាយការណ៍ខ្លី និងរាយការណ៍ជូនក្រុមប្រឹក្សាស្រុកក្នុងកិច្ចប្រជុំប្រចាំខែ | ▪ សមិទ្ធិផលសម្រេចបានក្នុងឆ្នាំកន្លងមក<br>▪ ផែនការអភិវឌ្ឍន៍ក្នុងសហគមន៍<br>▪ ការប្រើប្រាស់ថវិកា (ចំណូល ចំណាយ)សម្រាប់គម្រោងអភិវឌ្ឍន៍ឆ្នាំមុន និងបច្ចុប្បន្ន<br>▪ លទ្ធផលនៃការដោះស្រាយបញ្ហា ទាំងវិជ្ជមាន និងអវិជ្ជមាន |
| **៥) ផ្ទាំងព័ត៌មាន** | ក្តារព័ត៌មាន គឺជាមធ្យោបាយមួយដែលមានភាពសាមញ្ញ ចំណាយតិច និងអាចផ្សព្វផ្សាយព័ត៌មានបានច្រើនប្រភេទក្នុងពេលតែមួយ ដូច្នេះដើម្បីធានាថាព័ត៌មានដែលផ្សព្វផ្សាយមានប្រយោជន៍សម្រាប់ប្រជាពលរដ្ឋ ក្រុមប្រឹក្សាស្រុក៖<br>• កំណត់ប្រភេទព័ត៌មានសម្រាប់បិទផ្សាយ<br>• រៀបចំផែនការផ្លាស់ប្តូរព័ត៌មាន និងការចំណាយថតចម្លងឯកសារសម្រាប់បិទផ្សាយ<br>• រៀបចំផលិតព័ត៌មានសង្ខេប (ខ្លឹមសារខ្លី សាមញ្ញ) ទៅតាមការអនុម័តរបស់ក្រុមប្រឹក្សាស្រុក<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មាន យកព័ត៌មានតាមការអនុម័តរបស់ក្រុមប្រឹក្សាទៅបិទផ្សាយ<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មាន ផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋបានដឹង ដើម្បីទៅមើលព័ត៌មានបិទផ្សាយលើក្តារព័ត៌មាន តាមរយៈ ការចុះសង្កេតកាពិគ្រោះយោបល់នៅមូលដ្ឋានរបស់ក្រុមប្រឹក្សាឃុំ ការប្រជុំប្រចាំខែ វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ មេក្រូ និងបណ្តាញសហគមន៍មូលដ្ឋាន<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មាន ឱ្យតាមដានមើលការប្រើប្រាស់ (តើប្រជាពលរដ្ឋមើលព័ត៌មានបិទផ្សាយឬអត់) ដើម្បីផ្លាស់ប្តូរយុទ្ធសាស្ត្រ<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មានរៀបចំរបាយការណ៍ខ្លីសម្រាប់រាយការណ៍ជូនក្រុមប្រឹក្សាស្រុកក្នុងកិច្ចប្រជុំប្រចាំខែ | ខាងក្រោម គឺជាប្រភេទព័ត៌មានសក្តានុពលដែលក្រុមប្រឹក្សាស្រុកនឹងបិទផ្សាយតាមរយៈក្តារព័ត៌មាន៖<br>▪ ពេលវេលា និងទីកន្លែងនៃកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាស្រុក<br>▪ ពេលវេលា និងទីកន្លែងនៃការរៀបចំវេទិកា<br>▪ ពេលវេលា និងទីកន្លែងដែលក្រុមប្រឹក្សាស្រុកចុះសង្កេតការពិគ្រោះយោបល់នៅមូលដ្ឋាន<br>▪ កំណត់ហេតុសង្ខេបស្តីពី ប្រជុំប្រចាំខែ ប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាស្រុក<br>▪ កំណត់ហេតុសង្ខេបនៃ វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់<br>▪ តម្លៃសេវាសាធារណៈ<br>▪ ផែនការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន រួមទាំងគម្រោងដែលមានផលប៉ះពាល់ដល់ផលប្រយោជន៍ប្រជាពលរដ្ឋ<br>▪ ចំណូល ចំណាយរបស់ស្រុក<br>▪ ការសម្រេចនានា និងដីការ របស់ក្រុមប្រឹក្សាស្រុក<br>▪ សេចក្តីប្រកាស ឬសេចក្តីជូនដំណឹងផ្សេងៗរបស់ក្រុមប្រឹក្សាស្រុក |

| មធ្យោបាយជាយុទ្ធសាស្ត្រ | សកម្មភាពអនុវត្ត | ប្រភេទព័ត៌មានត្រូវផ្សព្វផ្សាយ |
|---|---|---|
| **៦) បណ្ដាញសហគមន៍មូលដ្ឋាន** | បណ្ដាញសហគមន៍មូលដ្ឋាន គឺជាមធ្យោបាយមួយដែលមានប្រសិទ្ធភាព ចំណាយថវិកាតិច ហើយអាចផ្សព្វផ្សាយព័តិមានបានដល់ប្រជាពលរដ្ឋដោយផ្ទាល់ ហេតុដូច្នេះទើបក្រុមប្រឹក្សាស្រុកតែងតែ ៖<br>• កំណត់ និងអនុម័តប្រភេទព័តិមានសម្រាប់ចែកជូនបណ្ដាញសហគមន៍មូលដ្ឋានចូលរួមប្រជុំប្រចាំខែ និងជាសមាជិកក្រុមផ្សព្វផ្សាយព័តិមាន<br>• អញ្ជើញតំណាងសហគមន៍មូលដ្ឋានចូលរួមក្នុងកិច្ចប្រជុំប្រចាំខែ<br>• អញ្ជើញតំណាងសហគមន៍មូលដ្ឋានចូលរួមក្នុងវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់<br>• ចែករំលែករបាយការណ៍សង្ខេបអំពីលទ្ធផលនៃកិច្ចប្រជុំប្រចាំខែ ដល់បណ្ដាញសហគមន៍មូលដ្ឋានយកផ្សព្វផ្សាយបន្ត<br>• ចែករំលែករបាយការណ៍សង្ខេបអំពីលទ្ធផលនៃវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ដល់បណ្ដាញសហគមន៍មូលដ្ឋាន យកទៅផ្សព្វផ្សាយបន្ត ក្នុងប្រជុំប្រចាំខែ<br>• ចាត់ក្រុមផ្សព្វផ្សាយព័តិមាន តាមដានមើលពីការផ្សព្វផ្សាយបន្តរបស់បណ្ដាញសហគមន៍មូលដ្ឋាន (តើព័តិមានបានដល់ប្រជាពលរដ្ឋ ឬអត់) ដើម្បីផ្លាស់ប្ដូរយុទ្ធសាស្ត្រ<br>• ចាត់ក្រុមផ្សព្វផ្សាយព័តិមានរៀបចំរបាយការណ៍ខ្លីសម្រាប់រាយការណ៍ជូនក្រុមប្រឹក្សាស្រុកក្នុងកិច្ចប្រជុំប្រចាំខែ ។ | ខាងក្រោម គឺជាប្រភេទព័តិមានសក្ដានុពលដែលក្រុមប្រឹក្សាស្រុកនឹងចែករំលែកដល់បណ្ដាញសហគមន៍មូលដ្ឋានដើម្បីយកទៅបិទផ្សាយបន្ត៖<br>▪ ពេលវេលា និងទីកន្លែងនៃប្រជុំប្រចាំខែ<br>▪ ពេលវេលា និងទីកន្លែងនៃវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់<br>▪ ពេលវេលា និងទីកន្លែងនៃការចុះសង្កេតការពិគ្រោះយោបល់នៅមូលដ្ឋាន<br>▪ កំណត់ហេតុសង្ខេបស្ដីពី លទ្ធផលនៃការប្រជុំប្រចាំខែ ឬប្រជុំវិសាមញ្ញដែលទាក់ទងនឹងផលប្រយោជន៍របស់ប្រជាពលរដ្ឋ<br>▪ កំណត់ហេតុសង្ខេបស្ដីពី លទ្ធផលនៃវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់<br>▪ តារាងតម្លៃសេវាសាធារណៈ<br>▪ ផែនការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន រួមទាំងផែនការអភិវឌ្ឍន៍ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ<br>▪ ចំណូល ចំណាយរបស់ស្រុក<br>▪ ការសម្រេច និងដីការ របស់ក្រុមប្រឹក្សាស្រុក<br>▪ សេចក្ដីប្រកាស ឬសេចក្ដីជូនដំណឹងផ្សេងៗ ។ |

| មធ្យោបាយជាយុទ្ធសាស្ត្រ | សកម្មភាពអនុវត្ត | ប្រភេទព័ត៌មានត្រូវផ្សព្វផ្សាយ |
|---|---|---|
| **៧) ប្រព័ន្ធផ្សព្វផ្សាយ** | ប្រព័ន្ធផ្សព្វផ្សាយ ត្រូវបានក្រុមប្រឹក្សាស្រុកមើលឃើញថា ជាមធ្យោបាយបញ្ជូនព័ត៌មានដ៏មានប្រសិទ្ធភាព បានលឿន ទាន់ពេលវេលា និងបានទូលំទូលាយទូទាំងប្រទេស ហេតុដូច្នេះទើបក្រុមប្រឹក្សាស្រុក៖<br>• កំណត់ប្រភេទព័ត៌មានសម្រាប់ផ្សព្វផ្សាយតាមបណ្តាញប្រព័ន្ធផ្សព្វផ្សាយ<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មានផលិតព័ត៌មានសម្រាប់ចែករំលែកដល់ក្រុមអ្នកសារព័ត៌មាន<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មានរៀបចំលិខិត ដើម្បីអញ្ជើញ និងជូនដំណឹងដល់ប្រព័ន្ធផ្សព្វផ្សាយឱ្យចូលរួមយកព័ត៌មានក្នុង៖<br>    ○ កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាស្រុក<br>    ○ វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់<br>    ○ សិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគស្រុក<br>    ○ វគ្គបណ្តុះបណ្តាល ឬព្រឹត្តិការណ៍ផ្សេងៗរបស់ក្រុមប្រឹក្សាស្រុក ។ល។<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មានឱ្យតាមដានការផ្សព្វផ្សាយបន្តរបស់ប្រព័ន្ធផ្សព្វផ្សាយ និងប្រមូលចងក្រងទុកជាឯកសារ<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មានឱ្យរៀបចំរបាយការណ៍ខ្លីសម្រាប់រាយការណ៍ជូនក្រុមប្រឹក្សាស្រុកក្នុងកិច្ចប្រជុំប្រចាំខែ | ខាងក្រោម គឺជាប្រភេទព័ត៌មានសក្តានុពលដែលក្រុមប្រឹក្សាស្រុកនឹងចែករំលែកដល់ប្រព័ន្ធផ្សព្វផ្សាយដើម្បីយកទៅផ្សព្វផ្សាយបន្ត៖<br>▪ តួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាស្រុក<br>• សមិទ្ធផលសម្រេចបានក្នុងឆ្នាំកន្លងមករបស់ក្រុមប្រឹក្សាស្រុក<br>• ការប្រើប្រាស់ថវិកា (ចំណូល ចំណាយ)សម្រាប់គម្រោងអភិវឌ្ឍន៍ឆ្នាំមុន និងបច្ចុប្បន្ន<br>• លទ្ធផលនៃការដោះស្រាយបញ្ហា ទាំងវិជ្ជមាន និងអវិជ្ជមាន<br>• លទ្ធផលនៃការប្រជុំប្រចាំខែ ឬប្រជុំវិសាមញ្ញដែលទាក់ទងនឹងផលប្រយោជន៍របស់ប្រជាពលរដ្ឋ<br>• លទ្ធផលនៃវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់<br>• តារាងតម្លៃសេវាសាធារណៈ<br>• ផែនការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន រួមទាំងផែនការអភិវឌ្ឍន៍ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ<br>• ការសម្រេច និងដីការ របស់ក្រុមប្រឹក្សាស្រុក<br>• សេចក្តីប្រកាស ឬសេចក្តីជូនដំណឹងផ្សេងៗ |



ಽ

## ឧបសម្ព័ន្ធ "ខ"÷ សេចក្តីស្រង់លំអិតអំពីមាត្រានានានៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ពីការផ្សព្វផ្សាយព័ត៌មាន

មាត្រា៣៦: រៀងរាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាត្រូវធ្វើសេចក្តី ឬដីការតាមការចាំបាច់ដែលទាក់ទិនទៅនឹង៖

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មី ស្របតាមច្បាប់នេះ
- មុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា
- មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា
- កម្មវិធីវិនិយោគបី (៣) ឆ្នាំរំកិលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍរយៈពេលប្រាំ (៥) ឆ្នាំ រួមទាំងសមាសភាពនៃផែនការនោះ ដែលស្ថិតនៅក្រោមនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សារួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត ក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា
- គម្រោងថវិកាប្រចាំឆ្នាំ និងក្របខណ្ឌចំណាយរយៈពេលមធ្យម
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀត
- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងគណៈកម្មាធិការអង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា
- ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ
- <u>ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែលសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋ</u>
- កិច្ចការផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដែលបានធ្វើឡើងស្របតាមច្បាប់នេះ ។

មាត្រា៤១: ក្រុមប្រឹក្សា ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់ នូវផែនការអភិវឌ្ឍន៍បន្ទាប់ពីបានអនុម័តរួចហើយភ្លាម ។ សាធារណជន អាចពិនិត្យឯកសារផែនការនេះ នៅការិយាល័យរបស់ក្រុមប្រឹក្សាដោយឥតគិតថ្លៃ ឬអាចស្នើសុំជាឯកសារផែនការនេះពីក្រុមប្រឹក្សាដោយគិតត្រឹមតម្លៃដើម ។

មាត្រា៥១ : ក្រុមប្រឹក្សាត្រូវបង្កលក្ខណៈងាយស្រួលដល់សាធារជនក្នុងការជូនព័ត៌មានជាសាធារណៈ នូវរបាយការណ៍ របៀបវារៈប្រជុំ កំណត់ហេតុប្រជុំ ដីកា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសទាំងអស់ ដែលពាក់ព័ន្ធនឹងក្រុមប្រឹក្សា និងឯកសារដទៃទៀតរបស់ក្រុមប្រឹក្សា ។

មាត្រា៥២: ក្រុមប្រឹក្សានីមួយៗ ត្រូវមានក្តារព័ត៌មានជាសាធារណៈ ឬមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងទៀតនៅការិយាល័យកណ្តាលរបស់ខ្លួន និងនៅតាមទីកន្លែងនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមការចាំបាច់ ហើយទីកន្លែងទាំងនោះមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋទទួលបានព័ត៌មានជាសាធារណៈទាំងនោះ ។

មាត្រា៧៦: ក្រុមប្រឹក្សាត្រូវផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់នូវប្រតិទិននៃការប្រជុំសាមញ្ញរបស់ខ្លួន ។

មាត្រា១៦៩: គណៈអភិបាលត្រូវធានាឱ្យមានក្តារបិទផ្សាយព័ត៌មាន និងមធ្យោបាយផ្សព្វផ្សាយព័ត៌មាន ផ្សេងៗទៀត តាមតម្រូវការរបស់ក្រុមប្រឹក្សារបស់ខ្លួន ។ រាល់ឯកសារទាំងអស់ដែលបានបោះពុម្ពផ្សាយស្របតាមច្បាប់នេះ ត្រូវតែបិទផ្សាយនៅលើក្តារព័ត៌មាន ឬត្រូវផ្សព្វផ្សាយតាមមធ្យោបាយផ្សេងៗទៀតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។

មាត្រា១៧០ : គណៈអភិបាលត្រូវធានាឱ្យសាធារណជន មានលទ្ធភាពគ្រប់គ្រាន់ក្នុងការពិនិត្យមើលព័ត៌មាននានា នៅលើក្តារបិទផ្សាយព័ត៌មាន ហើយត្រូវធានាថែរក្សាការពារសុវត្ថិភាពក្តារព័ត៌មាន ដែលមានក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។

---------------------

ឧបសម្ព័ន្ធ "គ"÷ សេចក្ដីសម្រេច និងលក្ខខណ្ឌការងារក្រុមការងារផ្សព្វផ្សាយព័ត៌មាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តបាត់ដំបង
សាលាស្រុកសង្កែ
លេខ: ០២៥ ......សសរ.សក

## សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតក្រុមផ្សព្វផ្សាយព័ត៌មានស្រុកសង្កែ

## ប្រធានក្រុមប្រឹក្សាស្រុកសង្កែ

-យោងព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការ គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-យោងអនុក្រឹត្យលេខ ៥៥៣ អនក្រ. តត ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ របស់ រាជរដ្ឋាភិបាល ស្ដីពីការទទួលស្គាល់ សមាសភាពក្រុមប្រឹក្សាស្រុកសង្កែ

-យោងអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ របស់រាជរដ្ឋាភិបាលស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនង ការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សាគណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក

-យោងអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពី "ការសហការ និងគាំទ្រអនុវត្តគម្រោង លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ក្រុង/ស្រុក នៃខេត្តបាត់ដំបង" រវាងអង្គការអេមរ៉ា ជាមួយនឹងរដ្ឋបាលស្រុកសង្កែ

-យោងការអនុម័តបង្កើតក្រុមផ្សព្វផ្សាយព័ត៌មានស្រុកសង្កែក្នុងកិច្ចប្រជុំសាមញ្ញលើកទី ៥០ របស់ក្រុមប្រឹក្សាស្រុកសង្កែ កាលពីថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ ។

## ស ម្រេ ច

**ប្រការ ១ :**

បង្កើតក្រុមផ្សព្វផ្សាយព័តិស្រុកសង្កែ មានដែលមានសមាសភាពដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១- | លោកស្រី | **សុំ ចិន្តា** | អភិបាលរងស្រុក | ជាប្រធាន |
| ២- | លោក | **គ្រួច គាដ** | សមាជិកក្រុមប្រឹក្សាស្រុក | ជាអនុប្រធាន |
| ៣- | លោក | **គង់ សុគន្ធា** | នាយករងរដ្ឋបាលសាលាស្រុក | ជាលេខាធិការ |
| ៤- | លោកស្រី | **ពា សោផៃ** | ប្រធានសហគមន៍ទឹកស្អាតក្រោមដី | ជាសមាជិក |
| ៥- | លោក | **អ៊ុន លីន** | មន្ត្រីមន្ទីរព័តិមានខេត្ត | ជាសមាជិក |

**<u>ប្រការ ២</u> :**

ក្រុមផ្សព្វផ្សាយព័ត៌មានស្រុកសង្កែ មានភារកិច្ច :

- រៀបចំផែនការសកម្មភាព ឱ្យបានត្រឹមត្រូវ ច្បាស់លាស់
- ផ្សព្វផ្សាយព័ត៌មាន ដល់ប្រជាពលរដ្ឋ ក្នុងស្រុកសង្កែ និងប្រមូលព័ត៌មានត្រឡប់មកវិញ ឱ្យកាន់តែមានប្រសិទ្ធភាព ដូចមានចែងក្នុងមាត្រា ៣៦ ,៤១, ៥១, ៥២, ៧៦, ១៦៩, ១៧០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- សហការល្អ ជាមួយអង្គការ អមរា តាមស្មារតីអនុស្សរណៈនៃការយោគយល់គ្នា
- ប្រជុំប្រចាំខែ បូកសរុបលទ្ធផលនៃការផ្សព្វផ្សាយ ប្រមូលព័ត៌មាន និង រាយការណ៍ជូនក្រុមប្រឹក្សា នៅរៀងរាល់កិច្ចប្រជុំសាមញ្ញ របស់ក្រុមប្រឹក្សា
- ការិយាល័យបំពេញការងារ របស់ក្រុមផ្សព្វផ្សាយព័ត៌មាននេះ ស្ថិតនៅក្រោមការរៀបចំរបស់គណៈអភិបាលស្រុក ។

**<u>ប្រការ ៣</u> :**

ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក និងអស់លោក ដូចមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

សង្កែ , ថ្ងៃទី១៥ ខែ សីហា ឆ្នាំ ២០១៣

**ប្រធានក្រុមប្រឹក្សាស្រុក**

**<u>ចម្លងជូន</u>**

-ក្រសួងមហាផ្ទៃ

-សាលាខេត្តបាត់ដំបង

«<u>ដើម្បីគោរពជូនជ្រាប</u>»

-ដូចប្រការ១ និងប្រការ៣

-ឃុំទាំង ១០ ក្នុងស្រុក

«<u>ដើម្បីអនុវត្ត</u>»

-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្របខ័ណ្ឌក្រុមផ្សព្វផ្សាយព័ត៌មានថ្នាក់ស្រុក

----

## ១. សេចក្តីផ្តើម

ផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានីក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌរាជរដ្ឋាភិបាលបានរៀបចំឱ្យមានរចនាសម្ព័ន្ធរដ្ឋបាលដែលនៅកៀក នឹងប្រជាពលរដ្ឋដើម្បីបង្កើនតម្លាភាព និងជំរុញការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

អនុលោមតាមអនុក្រឹត្យលេខ ២១៦ អ.ន.ក្រ ស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក មាត្រា ១៣៧បានចែងថា ក្រៅពីគណៈកម្មាធិការទាំងបីដែលមានរួចហើយ ក្រុមប្រឹក្សាអាចបង្កើតគណៈកម្មាធិការបន្ថែមផ្សេងទៀតតាមការចាំបាច់។ លើសពីនេះមាត្រា១៣៨ ក៏បានបន្ថែមថា ក្រុមប្រឹក្សាក្រុង ស្រុកអាចតែងតាំងសមាជិកក្រុមប្រឹក្សាក្រុង ស្រុក អភិបាលក្រុងស្រុក អភិបាលរងក្រុង ស្រុក តំណាងក្រុមប្រឹក្សា ឃុំ សង្កាត់ បុគ្គលិករបស់ក្រុមប្រឹក្សា ក្រុង ស្រុក តំណាងសហគមន៍មូលដ្ឋាន តំណាងប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាតាមការចាំបាច់សម្រាប់សមាជិក ក្រុមការងារដែលខ្លួនបានបង្កើតឡើង។

ក្រុមប្រឹក្សាស្រុក ត្រូវសម្រេចពីចំនួនសមាជិកក្រុមការងារនីមួយៗ ការតែងតាំងប្រធាន អនុប្រធាន និងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមការងារនានាដែលខ្លួនបានបង្កើតឡើង។

ក្រុមការងារនីមួយៗត្រូវមានតំណាងស្ត្រីសមស្របរួមទាំងប្រធាន អនុប្រធានក្រុមការងារផង។

ក្រុមប្រឹក្សាស្រុក អាចរំលាយក្រុមការងារ និងអាចបញ្ឈប់សមាជិកណាម្នាក់ពី ក្រុមការងារដែលខ្លួនបានបង្កើតឡើងតាមការចំបាច់ ឬតាមសំណើរបស់គណៈកម្មាធិការ ឬគណៈអភិបាលស្រុក ។

ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៩២បានចែងថា ក្រុមប្រឹក្សានីមួយៗត្រូវមានក្តារព័ត៌មានជាសាធារណៈឬមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងទៀតនៅការិយាល័យកណ្តាលរបស់ខ្លួនតាមការចាំបាច់ ហើយទីកន្លែងទាំងនោះមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋទទួលបានព័ត៌មានជាសាធារណៈទាំងនោះ។

ការផ្សព្វផ្សាយព័ត៌មានរបស់ក្រុមប្រឹក្សាស្រុក ជាយន្តការមួយដ៏មានប្រសិទ្ធភាពដើម្បីអាចឱ្យប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចបានដឹងពី ស្ថានភាព និងលទ្ធផលនៃការអភិវឌ្ឍន៍របស់ខ្លួន និងបង្ហាញពីតម្លាភាពចំណូល ចំណាយដល់មូលដ្ឋាន។ ការផ្សព្វផ្សាយព័ត៌មានជាមធ្យោបាយក្នុងការកៀរគរប្រជាពលរដ្ឋឱ្យចូលរួមក្នុងសកម្មភាពរបស់ក្រុមប្រឹក្សា និងប្រើប្រាស់សេវាដែលក្រុមប្រឹក្សាស្រុក បានផ្តល់ និងសហគមន៍មូលដ្ឋានមានលទ្ធភាពក្នុងការផ្តល់ព័ត៌មានត្រលប់ពីគុណភាពនៃការផ្តល់សេវារបស់ក្រុមប្រឹក្សាមកវិញ។

## ២. គោលបំណងនៃការបង្កើតក្រុមផ្សព្វផ្សាយព័ត៌មាន

ដើម្បីផ្សព្វផ្សាយព័ត៌មានស្តីពីសកម្មភាពអភិវឌ្ឍន៍ និងលទ្ធផលនានាដែលក្រុមប្រឹក្សាសម្រេចបាន (ផែនការអភិវឌ្ឍកម្មវិធីវិនិយោគ ផែនការថវិកា ចំណូល ចំណាយ ប្រតិទិននៃការប្រជុំរបស់ក្រុមប្រឹក្សាក្រុង ព្រឹត្តិការណ៍នានារបស់ក្រុមប្រឹក្សាស្រុក ការចេញដីកា សេចក្តីសម្រេច ការសម្រេចចិត្តនានា ។ល។) ។

## ៣. សមាសភាពក្រុមផ្សព្វផ្សាយព័ត៌មាន

ចំនួនសមាជិកក្រុមផ្សព្វផ្សាយព័ត៌មាន អាស្រ័យលើតម្រូវការជាក់ស្តែង អនុម័តដោយក្រុមប្រឹក្សាស្រុក។ សមាសភាពក្រុមប្រឹក្សាផ្សព្វផ្សាយព័ត៌មានរួមមាន៖

- គណៈអភិបាលទទួលបន្ទុកផ្នែកព័ត៌មាន (១រូប) ជាប្រធាន
- សមាជិកក្រុមប្រឹក្សាស្រុក (១រូប) ជាអនុប្រធាន
- នាយករងរដ្ឋបាល (១រូប) ជា លេខាធិការ
- តំណាងមន្ទីរព័ត៌មាន អ្នកសារព័ត៌មាន (១រូប) ជា សមាជិក
- តំណាងអង្គការសហគមន៍មូលដ្ឋាន(១រូប) ជា សមាជិក

## ៤.តួនាទី និងភារកិច្ចរបស់ក្រុមផ្សព្វផ្សាយព័ត៌មាន

### ប្រធានក្រុមផ្សព្វផ្សាយព័ត៌មាន

- ដឹកនាំ និងគ្រប់គ្រងក្រុមផ្សព្វផ្សាយព័ត៌មានតាមមូលដ្ឋាន
- ផ្តល់ព័ត៌មានទាំងឡាយ ដែលបានកំណត់ក្នុងក្របខណ្ឌការងារដល់សមាជិកក្រុមផ្សព្វផ្សាយព័ត៌មានដើម្បីផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋ

- រាយការណ៍អំពីស្ថានភាពនៃការផ្សព្វផ្សាយព័ត៌មានជូនក្រុមប្រឹក្សាក្នុងកិច្ចប្រជុំប្រចាំខែ
- រៀបចំ និងចុះកិច្ចសន្យាជាមួយអ្នកផ្តល់សេវាផ្សព្វផ្សាយព័ត៌មាន (ឧទាហរណ៍: ការផ្សព្វផ្សាយព័ត៌មានតាមមេក្រូ )
- ស្នើសុំថវិកាបម្រុងសម្រាប់គាំទ្រដល់ការថតចម្លងឯកសារព័ត៌មានការបោះពុម្ពសម្ភារៈអប់រំអំពីតួនាទីភារៈកិច្ចនិងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ។
- រៀបចំកិច្ចប្រជុំក្រុមផ្សព្វផ្សាយព័ត៌មានជាទៀងទាត់ នៅមុនពេលកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា ដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាព និងបូកសរុបនៃកាផ្សព្វផ្សាយរៀបចំរបាយការណ៍ ឬកំណត់ហេតុសម្រាប់រាយការណ៍ក្នុងកិច្ចប្រជុំប្រចាំខែ

**សមាជិកក្រុមផ្សព្វផ្សាយព័ត៌មាន** (តំណាងក្រុមប្រឹក្សាសង្កាត់ តំណាងអង្គការសហគមន៍មូលដ្ឋាន)

- ពាំនាំព័ត៌មានពីក្រុមប្រឹក្សាក្រុង យកទៅផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋជាទៀងទាត់
- ផ្តល់យោបល់ត្រឡប់ និងរាយការណ៍អំពីមតិយោបល់របស់ប្រជាពលរដ្ឋអំពីការផ្សព្វផ្សាយព័ត៌មាន
- ចូលរួមក្នុងកិច្ចប្រជុំតាមការកោះអញ្ជើញរបស់ប្រធានក្រុមផ្សព្វផ្សាយព័ត៌មាន

**សមាជិកក្រុមផ្សព្វផ្សាយព័ត៌មាន**(អ្នកសារព័ត៌មាន)

- ចូលរួមយកព័ត៌មាននិងផ្សព្វផ្សាយអំពីលទ្ធផលនៃកិច្ចប្រជុំប្រចាំខែ និងសកម្មភាពរបស់ក្រុមប្រឹក្សាដទៃទៀតតាមការអញ្ជើញរបស់ក្រុមប្រឹក្សា
- ជួយផ្សព្វផ្សាយព័ត៌មានដែលផ្តល់ដោយប្រធានក្រុមផ្សព្វផ្សាយព័ត៌មាន បន្តដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ។

## ៥. ប្រភេទនិងមធ្យោបាយផ្សព្វផ្សាយព័ត៌មាន

### ៥.១ ប្រភេទព័ត៌មានដែលត្រូវផ្សព្វផ្សាយ

- របៀបវារៈ និងកាលបរិច្ឆេទនៃកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់កិច្ចប្រជុំនានារបស់ក្រុមប្រឹក្សា រួមបញ្ចូលកិច្ចប្រជុំវិសាមញ្ញពាក់ព័ន្ធនឹងផលប៉ះពាល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ
- កំណត់ហេតុសង្ខេបអំពីប្រជុំប្រចាំខែនិងកិច្ចប្រជុំនានា ទាក់ទងនឹងការសម្រេចចិត្តនានារបស់ក្រុមប្រឹក្សាដែលមានឥទ្ធិពល ឬផលប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ
- តួនាទីនិងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាស្រុក

- គម្រោងអភិវឌ្ឍក្នុងមូលដ្ឋានដូចជា៖ការស្ថាបនា ស្ពាន ថ្នល់ ទំនប់ ប្រឡាយ ប្រព័ន្ធលូធារាសាស្ត្រសម្បទានដីធ្លីរបស់រាជរដ្ឋាភិបាល។
- ប្រកាសជូនដំណឹងគម្រោងអភិវឌ្ឍដែលអនុម័តឬសម្រេចដាក់ចូលក្នុងផែនការវិនិយោគស្រុក និងឃុំ
- គម្រោងផែនការថវិកាចំណូលចំណាយរបស់ក្រុមប្រឹក្សាស្រុក និងឃុំ
- អត្រាតម្លៃសេវាសាធារណៈរបស់ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំនិងតម្លៃដែលបានកំណត់ដោយរាជរដ្ឋាភិបាល
- សន្តិសុខសុវត្ថិភាពសុខភាពអប់រំទឹកស្អាតនិងអនាម័យទូទៅរបស់ប្រជាពលរដ្ឋ
- ព័ត៌មានទាក់ទងនឹងផលប្រយោជន៍ និងតម្រូវការរបស់ក្រុមជនងាយរងគ្រោះ
- កម្មវិធីវិនិយោគក្រុមប្រឹក្សាស្រុក
- ចំណាត់ការ និងដំណោះស្រាយ
- ។ល។

## ៥.២ មធ្យោបាយផ្សព្វផ្សាយព័ត៌មាន

យោងតាមក្របខណ្ឌការងារនេះ សមាជិកក្រុមផ្សព្វផ្សាយព័ត៌មានគឺជាភ្នាក់ងារធានាការផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពការងាររបស់ក្រុមប្រឹក្សាដល់ប្រជាពលរដ្ឋ តាមរយៈសារព័ត៌មាន ព្រឹត្តិប័ត្រ គេហទំព័រ វិទ្យុ ទូរទស្សន៍ ក្តារព័ត៌មាន មេក្រូ ការចុះពិគ្រោះយោបល់នៅមូលដ្ឋាន វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ វេទិកា កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា និងបណ្តាញអង្គការសហគមន៍មូលដ្ឋាន។

ក្របខណ្ឌការងាររបស់ក្រុមផ្សព្វផ្សាយព័ត៌មានថ្នាក់ក្រុង នេះ ត្រូវបានអនុម័តដោយយោងតាមស្មារតីអង្គប្រជុំរបស់ក្រុមប្រឹក្សាស្រុក នាថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣។

# អនុស្សរណៈយោគយល់គ្នា

## ស្តីពី

## ការសហការនិងផ្សព្វផ្សាយព័ត៌មាន

## ស្តីពី

## សកម្មភាពអភិវឌ្ឍន៍ និងលទ្ធផលនានាដែលក្រុមប្រឹក្សាសម្រេចបាន ក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## ស្រុកសង្កែ ខេត្តបាត់ដំបង

ថ្ងៃទី០១ខែសីហាឆ្នាំ២០១៣ - ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥

## រវាង

## រដ្ឋបាលស្រុកសង្កែ

## និង

## មន្ទីរព័ត៌មាន ខេត្តបាត់ដំបង

**គាំទ្រមូលនិធិដោយ:** ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ ដើម្បីអភិវឌ្ឍន៍របស់ប្រទេសស៊ុយអែត (Sida)

៥

ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៥២បានចែងថា ក្រុមប្រឹក្សានីមួយៗ ត្រូវមានក្តារព័ត៌មានជាសាធារណៈឬមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងទៀតនៅការិយាល័យកណ្តាលរបស់ខ្លួនតាមការចាំបាច់ ហើយទីកន្លែងទាំងនោះមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋទទួលបានព័ត៌មានជាសាធារណៈទាំងនោះ ។ ការផ្សព្វផ្សាយព័ត៌មានរបស់ក្រុមប្រឹក្សាស្រុក ជាយន្តការមួយដ៏មានប្រសិទ្ធភាព ដើម្បីអាចឱ្យប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចបានដឹងពីស្ថានភាព និងលទ្ធនៃការអភិវឌ្ឍរបស់ខ្លួន និងបង្ហាញពីតម្លាភាពចំណូល ចំណាយដល់មូលដ្ឋាន ។ការផ្សព្វផ្សាយព័ត៌មានជាមធ្យោបាយ ក្នុងការកៀរគរប្រជាពលរដ្ឋឱ្យចូលរួមក្នុងសកម្មភាពរបស់ក្រុមប្រឹក្សាស្រុក និងប្រើប្រាស់សេវាដែលក្រុមប្រឹក្សាស្រុកបានផ្តល់ និងសហគមន៍មូលដ្ឋានមានលទ្ធភាពក្នុងការផ្តល់ព័ត៌មានត្រឡប់ពីគុណភាពនៃការផ្តល់សេវារបស់ក្រុមប្រឹក្សាស្រុកមកវិញ ។

ក្រុមប្រឹក្សាស្រុកនៃស្រុកសង្កែ ខេត្តបាត់ដំបង និងមន្ទីរព័ត៌មានខេត្តបាត់ដំបងបានធ្វើការប្តេជ្ញាចិត្តរបស់ខ្លួនដើម្បីលើកកម្ពស់សិទ្ធិទទួលបានព័ត៌មាន ការផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយដល់សាធារណៈជនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងសកម្មភាពរបស់ក្រុមប្រឹក្សាស្រុកសង្កែតាមរយៈប្រព័ន្ធផ្សព្វផ្សាយវិទ្យុ និងទូរទស្សន៍នានាដែលស្ថិតនៅក្រោមឱវាទរបស់មន្ទីរព័ត៌មានខេត្តបាត់ដំបងស្តីពី“***សកម្មភាពអភិវឌ្ឍន៍ និងលទ្ធផលនានាដែលក្រុមប្រឹក្សាសម្រេចបាន ក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ***” ។

ដើម្បីឱ្យដំណើរការនៃការលើកកម្ពស់សិទ្ធិទទួលបានព័ត៌មាន ការផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយដល់សាធារណៈជនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋជាមួយសកម្មភាពរបស់ក្រុមប្រឹក្សាស្រុកឱ្យកាន់តែមានប្រសិទ្ធភាព ក្រុមប្រឹក្សាស្រុកសង្កែ ខេត្តបាត់ដំបង និងមន្ទីរព័ត៌មានខេត្តបាត់ដំបងសូមធ្វើការប្តេជ្ញាចិត្តដូចខាងក្រោម៖

**១.ការសហការ និងប្តេជ្ញាចិត្តរបស់មន្ទីរព័ត៌មានខេត្តបាត់ដំបង**

- ចូលរួមដើម្បីយកព័ត៌មានជាប្រចាំនូវរាល់សកម្មភាពអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាស្រុកសង្កែទាំងអស់
- សហការ និងចាត់មន្ត្រីភ្នាក់ងារ ក្រុមអ្នកយក ឬផលិតព័ត៌មាន នៃមន្ទីរព័ត៌មានខេត្តបាត់ដំបង ឬតំណាងស្ថានីយ៍វិទ្យុ និងទូរទស្សន៍នានាដើម្បីចូលរួមផលិត និងផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណៈជន ជាពិសេសប្រជាពលរដ្ឋក្នុងស្រុកសង្កែ ឱ្យបានដឹងអំពីសកម្មភាពអភិវឌ្ឍន៍ និងលទ្ធផលនានាដែលក្រុមប្រឹក្សាស្រុកសង្កែសម្រេចបានក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។
- ចូលរួមក្នុងការបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិជាមួយក្រុមប្រឹក្សាស្រុក

**ក.ប្រភេទព័ត៌មានដែលត្រូវផ្សព្វផ្សាយរួមមាន៖**

- របៀបវារៈនិងកាលបរិច្ឆេទនៃកិច្ចប្រជុំប្រចាំខែនិងកិច្ចប្រជុំកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាស្រុក និងឃុំ



ស

- កាលបរិច្ឆេទនៃវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាក្រុង និងសង្កាត់កំណត់ហេតុសង្ខេបអំពីប្រជុំប្រចាំខែនិងកិច្ចប្រជុំនានាទាក់ទងនឹងការសម្រេចចិត្តនានារបស់ក្រុមប្រឹក្សាដែលមានឥទ្ធិពល ឬផលប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ
- តួនាទីនិងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាស្រុក
- គម្រោងអភិវឌ្ឍន៍ក្នុងមូលដ្ឋានដូចជាៈ ការស្ថាបនា ស្ពាន ថ្នល់ ទំនប់ ប្រឡាយប្រព័ន្ធលូធារាសាស្ត្រសម្បទានដីធ្លីរបស់រាជរដ្ឋាភិបាល ។
- ប្រកាសជូនដំណឹងគម្រោងអភិវឌ្ឍន៍ដែលអនុម័តឬសម្រេចដាក់ចូលក្នុងផែនការវិនិយោគឃុំ ស្រុក
- គម្រោងផែនការថវិកាចំណូលចំណាយរបស់ក្រុមប្រឹក្សាស្រុក និងឃុំ
- អត្រាតម្លៃសេវាសាធារណៈរបស់ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់និងតម្លៃដែលបានកំណត់ដោយរាជរដ្ឋាភិបាល
- សន្តិសុខ សុវត្ថិភាព សុខភាព អប់រំទឹកនិងអនាម័យរបស់ប្រជាពលរដ្ឋ
- ព័ត៌មានទាក់ទងនឹងផលប្រយោជន៍ និងតម្រូវការរបស់ក្រុមជនងាយរងគ្រោះ
- កម្មវិធីវិនិយោគក្រុមប្រឹក្សាស្រុក
- ចំណាត់ការ និងដំណោះស្រាយ

**ខ. មធ្យោបាយផ្សព្វផ្សាយព័ត៌មាន**

មន្ទីរព័ត៌មានខេត្តបាត់ដំបង គឺជាភ្នាក់ងារធានាការផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពអភិវឌ្ឍន៍ និងលទ្ធផលនានាដែលក្រុមប្រឹក្សាស្រុកសង្កែសម្រេចបាន ក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដល់ប្រជាពលរដ្ឋ តាមរយៈវិទ្យុនិងទូរទស្សន៍នានាឬតាមមធ្យោបាយផ្សេងៗទៀត ក្នុងការលើកកម្ពស់សិទ្ធិទទួលបានព័ត៌មាន តម្លាភាព បង្កើនការចូលរួមនិងចំណាប់អារម្មណ៍របស់ប្រជាពលរដ្ឋលើអភិបាលកិច្ចល្អនៅថ្នាក់ស្រុក និងឃុំ ។

**៤.ការប្តេជ្ញាចិត្តរបស់ក្រុមប្រឹក្សាស្រុកបាត់ដំបង**

ដើម្បីបង្កលក្ខណៈ និងភាពងាយស្រួលដល់មន្ត្រីអ្នកសារព័ត៌មានភ្នាក់ងារឬក្រុមអ្នកយកនិងផលិតព័ត៌មានដើម្បីចាក់ផ្សព្វផ្សាយតាមប្រព័ន្ធវិទ្យុនិងទូរទស្សន៍បានរហ័សហើយទាន់ពេលវេលាក្រុមប្រឹក្សាស្រុកសង្កែនៃខេត្តបាត់ដំបងជាអ្នកធានាសហការនិងផ្តល់ជូនទូវមន្ត្រីទទួលបន្ទុកនិងព័ត៌មានត្រូវផ្សព្វផ្សាយដូចតទៅៈ

- ចាត់តាំងឱ្យមានក្រុមប្រឹក្សាស្រុក មន្ត្រីទទួលបន្ទុកព័ត៌មាន១រូប ឬច្រើនរូប ដើម្បីសហការនិងផ្តល់ព័ត៌មានជូនភ្នាក់ងារអ្នកយកព័ត៌មានដែលស្ថិតនៅក្រោមឱវាទរបស់មន្ទីរព័ត៌មានខេត្ត
- ផ្តល់ព័ត៌មានជាមុន ឬជាប្រចាំអំពីសកម្មភាពអភិវឌ្ឍរបស់ខ្លួនដល់អ្នកសារព័ត៌មានដើម្បីបង្កលក្ខណៈអាចឱ្យអ្នកសារព័ត៌មានទទួលបានព័ត៌មានទាន់ពេល



ई

- រាល់សកម្មភាពបណ្តុះបណ្តាលដែលរៀបចំដោយរដ្ឋបាលក្រុងសហការជាមួយអង្គការនានាត្រូវអញ្ជើញឱ្យមានអ្នកសារព័ត៌មានចូលរួមក្នុងការរៀនសូត្រ និងយកព័ត៌មានដើម្បីផ្សព្វផ្សាយជូនសាធារណៈជន
- ផ្តល់ព័ត៌មានបច្ចុប្បន្នភាពជាប្រចាំស្តីពីគម្រោង (លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ)ជូនដល់អ្នកសារព័ត៌មាន

## ៤.អំពីការគាំទ្រ សហការ÷

- ➤ ក្នុងការចូលរួមចំណែកក្នុងការពង្រឹង និងលើកកម្ពស់សិទ្ធិទទួលបាន ប្រសិទ្ធភាព និងតម្លាភាព រដ្ឋបាលស្រុកសង្កែនឹងធ្វើការចំណាយសម្រាប់រាល់កម្មវិធីចាក់ផ្សាយព័ត៌មានប្រព័ន្ធវិទ្យុ និងទូរទស្សន៍ និងធ្វើការចំណាយសម្រាប់មធ្យោបាយធ្វើដំណើរចុះបេសកកម្មផលិតព័ត៌មានអំពីព្រឹត្តិការណ៍នានាពាក់ព័ន្ធនឹងសកម្មភាពរបស់ក្រុមប្រឹក្សាស្រុកសង្កែទៅតាមលទ្ធភាពរបស់រដ្ឋបាលស្រុក
- ➤ សហការជាដៃគូជាមួយអង្គការអមរាក្នុងការផ្សព្វផ្សាយពីសកម្មភាពរបស់ក្រុមប្រឹក្សាស្រុកឃុំ និង សហគមន៍
- ➤ ផ្តល់ជូននូវព័ត៌មានដែលចាក់ផ្សាយរួចជូនដល់អង្គការអមរាទុកជាឯកសារ

## ៥.អំពីវិវាទ÷

- ភាគីណាមួយ នៃភាគីទាំពីរ អាចស្នើសុំធ្វើការកែសម្រួលឡើងវិញនូវចំណុចណាមួយ ដែលភាគីមិនយល់សម្រប និងអាចអនុវត្តបានតាមអនុស្សរណៈយោគយល់គ្នាស្តីពីការសហការនិងផ្សព្វផ្សាយព័ត៌មានស្តីពីសកម្មភាពអភិវឌ្ឍន៍និងលទ្ធផលនានាដែលក្រុមប្រឹក្សាសម្រេចបាន ក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៃក្រុមប្រឹក្សាស្រុកសង្កែ
- ដើម្បីជាសក្ខីភាពភាគីទាំងពីរក្រុមប្រឹក្សាស្រុកសង្កែ និងមន្ទីរព័ត៌មាន ឬតំណាងមន្ទីរព័ត៌មានខេត្តបាត់ដំបងបានព្រមព្រៀងគ្នាចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាចាប់ពីពេលនេះតទៅ។

| | |
|---|---|
| ប្រធានក្រុមប្រឹក្សាស្រុកសង្កែ | ប្រធានមន្ទីរ ឬតំណាងមន្ទីរព័ត៌មានខេត្តបាត់ដំបង |
| ហត្ថលេខា................................ | ហត្ថលេខា................................ |
| ឈ្មោះ ................................ | ឈ្មោះ................................ |
| កាលបរិច្ឆេទ................................ | កាលបរិច្ឆេទ................................ |

# សកម្មភាពក្រុមផ្សព្វផ្សាយព័ត៌មានចល័តរបស់រដ្ឋបាលស្រុកសង្កែ

ទីតាំងវត្តអូរមុនី ភូមិអូរមុនី ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង



